# អនុស្សរណៈនៃការយោគយល់គ្នា

## រវាង

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ
## ការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ
## ការធ្វើអាជីវកម្មពលកម្មលើមនុស្ស
## និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
(ប.ជ.រ.ព.ភ)

## និង

## អង្គការវីនរ៉ក់ អន្តរជាតិ

សម្រាប់

## អនុវត្តកម្មវិធីប្រឆាំងការជួញដូរមនុស្ស(CTIP)
## នៅប្រទេសកម្ពុជា

*រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២*

## ១. សាវតា

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លា ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស នៅក្នុងប្រទេស ។ ក្នុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលកម្ពុជា គឺជាសមាជិកស្ថាបនិកមួយរបស់ COMMIT បានរៀបចំឱ្យមាននូវវិធានការជាច្រើន ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ សំដៅលើកកម្ពស់ សិទ្ធិមនុស្ស ភាពថ្លៃថ្នូរ និងការអភិវឌ្ឍន៍ ។ ក្រៅពីការចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការក្នុងតំបន់ និងនៅក្នុងប្រទេសកម្ពុជា កំណែទម្រង់ច្បាប់ត្រូវបានអនុវត្ត ដើម្បីដោះស្រាយបញ្ហាឧក្រិដ្ឋកម្មជួញដូរមនុស្ស និងការអនុម័តច្បាប់ប្រឆាំងការជួញដូរមនុស្សជាលើកទី២ បន្ទាប់ពីមានច្បាប់ប្រឆាំងការជួញដូរមនុស្សដំបូងក្នុងឆ្នាំ១៩៩៦ និងបានគូសបញ្ជាក់អំពីជំហានសំខាន់ៗ ដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត ដើម្បីនាំខ្លួនជនល្មើសទៅតុលាការ និងផ្តល់សំណងជូនដល់ជនរងគ្រោះ។ យន្តការបណ្តោះអាសន្នមួយចំនួន បានបង្កើតឡើងដោយមានការគាំទ្រ និងចូលរួមពីបណ្តាក្រសួងនានា អភិបាលរាជធានី/ខេត្ត និងក្រុមប្រឹក្សាឃុំ/សង្កាត់ដោយចង្អុលបង្ហាញចំពោះបញ្ហាកង្វល់របស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពបន្តទៀតទៅលើប្រជាពលរដ្ឋរបស់ខ្លួន និងការពារជនដែលត្រូវបានកេងប្រវ័ញ្ចរួចទៅហើយ។

នៅចុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយន្តការជាតិមួយគឺ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) និងមានលេខាធិការដ្ឋានថ្នាក់ជាតិមួយ ដើម្បីធ្វើការសម្របសម្រួលលើអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី ព្រមទាំងលើកកម្ពស់អភិក្រម មួយសម្រាប់ផ្តួចផ្តើមក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា ដែលយន្តការនេះ ត្រូវបានទទួលស្គាល់ថាជាសញ្ញាមួយទៀតនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ។

យោងតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្សក្នុងប្រទេសកម្ពុជា អនុស្សរណៈនៃការយោគយល់គ្នានេះ នឹងក្លាយទៅជាកិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ និងអង្គការវីនរ៉ក់អន្តរជាតិ (WI) សម្រាប់អនុវត្តន៍កម្មវិធីប្រឆាំងការជួញដូរមនុស្ស (CTIP-II) ។ អង្គការវីនរ៉ក់អន្តរជាតិជាអ្នកអនុវត្តគម្រោងប្រឆាំងការជួញដូរមនុស្ស (CTIP-II) របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានអនុវត្តតាម "កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក ស្តីពីជំនួយផ្នែកសេដ្ឋកិច្ច បច្ចេកទេស និងជំនួយពាក់ព័ន្ធ" ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ។

អង្គការវីនរ៉ក់អន្តរជាតិ (WI) តំណាងដោយនាយកគំពាងកម្មវិធី និងគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទស្ត្រី និងកុមារ នៃរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ (ភាគីអ្នកចូលរួម) គឺមានបំណងគាំទ្រ និងពង្រឹងការផ្តួចផ្តើមប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការសម្របសម្រួលកិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយក្រសួងសំខាន់ៗ និងសមាជិករបស់គណៈកម្មាធិការជាតិ គណៈកម្មាធិការរាជធានី/ខេត្ត ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាតិ/អន្តរជាតិនៅក្នុងប្រទេស ។

SA

ដូច្នេះ ភាគីអ្នកចូលរួមនៅក្នុងអនុស្សរណៈនៃការយោគយល់នេះ បានយល់ និងឯកភាពលើអនុស្សរណៈនៃការយោគយល់ (MOU) បច្ចុប្បន្ន ដោយគោរព នឹងគាំទ្រចំពោះគោលបំណងដែលបានកំណត់នៅក្នុងគោលដែលបានចែង។

## ២. គោលបំណង

ដោយអនុលោមតាមមូលនិធិ រាជរដ្ឋាភិបាលកម្ពុជា និងភាគីអ្នកចូលរួម មានគោលបំណងនឹងបន្តកិច្ចសហប្រតិបត្តិការជាថ្មីទៀត អង្គការវីនរ៉ក់អន្តរជាតិក៏បានបញ្ជាក់អំពីចេតនារបស់ខ្លួនក្នុងការគាំទ្រដល់កម្មវិធីប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២ (CTIP-II) រយៈពេល៤ឆ្នាំ ដែលត្រូវអនុវត្តក្នុងប្រទេសកម្ពុជា ។

គោលបំណងនៃអនុស្សរណៈនៃការយោគយល់នេះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការអនុវត្តន៍កម្មវិធីប្រឆាំងការជួញដូរមនុស្ស រវាងគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ នៃរាជរដ្ឋាភិបាលកម្ពុជា និងអង្គការវីនរ៉ក់ ព្រមទាំងដៃគូអនុវត្តដទៃទៀត នៅក្នុងគោលនយោបាយសម្របសម្រួល កិច្ចការពារ ការទប់ស្កាត់ ការផ្តន្ទាទោស និងការធ្វើសមាហរណកម្ម។

គោលដៅនៃកម្មវិធីប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២ (CTIP-II) គឺដើម្បីគាំទ្រការបង្កើនសមត្ថភាព និងការត្រៀមខ្លួនជាស្រេចរបស់ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងរាល់ទម្រង់នៃការជួញដូរមនុស្ស ដូចជា ៖

១. គាំទ្រដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ក្នុងការពង្រឹងសមត្ថភាព ដើម្បីរៀបចំ ដឹកនាំ សម្របសម្រួល និងវាយតម្លៃ ទៅលើកិច្ចខិតខំនៅក្នុងប្រទេស និងតំបន់ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងរាល់ទម្រង់នៃការជួញដូរមនុស្ស ។

២. លើកកម្ពស់សេវាការពារ និងថែទាំជនរងគ្រោះពីគ្រប់ទម្រង់នៃការជួញដូរមនុស្ស ។

៣. បង្កើនសមត្ថភាពអនុវត្តច្បាប់ ដើម្បីកំណត់អត្តសញ្ញាណ និងផ្តន្ទាទោសឈ្មួញជួញដូរ មនុស្ស និងបទល្មើស ដែលទាក់ទងទៅនឹងការជួញដូរមនុស្ស និង

៤. លើកកម្ពស់យុទ្ធសាស្ត្របង្ការនៅកម្រិតថ្នាក់ជាតិនិងថ្នាក់មូលដ្ឋានដើម្បីកាត់បន្ថយការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ។

*សូមមើលឧបសម្ព័ន្ធ ក ៖ សង្ខេបគម្រោងប្រឆាំងការជួញដូរមនុស្ស ដំណាក់កាលទី២។*

## ៣. ការទទួលខុសត្រូវរបស់ភាគីអ្នកចូលរួម

### ៣.១ ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិ

តាមរយៈការចុះហត្ថលេខាទៅលើអនុស្សរណៈនៃការយោគយល់គ្នានេះ គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ នៃរាជរដ្ឋាភិបាលកម្ពុជា យល់ព្រម ៖

- ទទួលស្គាល់ថា អង្គការវីនរ៉ក់គឺជាដៃគូ ហើយអង្គការនេះត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពប្រឆាំងការជួញដូរមនុស្ស និងអនុវត្តគម្រោងនេះ ព្រមទាំងសកម្មភាពដទៃទៀតនៅក្នុងប្រទេសកម្ពុជាក្រោម

SAC

កិច្ចសហការពីគណៈកម្មាធិការជាតិ និងក្រោមច្បាប់ និងនិយ័តកម្មនៃព្រះរាជាណាចក្រកម្ពុជា និងយោងទៅតាមបទប្បញ្ញត្តិ នៃអនុស្សរណៈនៃការ យោគយល់គ្នានេះ ។

- ជំនួយរបស់អង្គការវីនរ៉ក់ សមស្រប នៅក្នុងការអនុវត្តន៍កម្មវិធី និងសកម្មភាពដូចបានពិភាក្សាខាងលើ ។
- ការផ្តល់ព័ត៌មានពាក់ព័ន្ធស្តីពីសកម្មភាពប្រឆាំងការជួញដូរមនុស្សទៅវិញទៅមក រវាងអង្គការវីនរ៉ក់ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ និងពត៌មានពីម្ចាស់ជំនួយដទៃទៀតដែលធ្វើការពាក់ព័ន្ធគឺជាតម្រូវការចាំបាច់ ដើម្បីពង្រឹង និងសម្របសម្រួលសកម្មភាពដែលបានអនុវត្តក្រោមអនុស្សរណៈនៃការយោគយល់គ្នានេះ ។
- រៀបចំ និង/ឬលើកទឹកចិត្តឱ្យមានការចូលរួម និងគាំទ្រសម្រាប់សកម្មភាពដែលត្រូវបានអនុវត្តក្រោមអនុស្សរណៈនៃការយោគយល់គ្នានេះ ពីស្ថាប័នថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធ។

**៣.២ ការទទួលខុសត្រូវរបស់អង្គការវីនរ៉ក់អន្តរជាតិ**

តាមរយៈការចុះហត្ថលេខាទៅលើអនុស្សរណៈនៃការយោគយល់នេះ អង្គការវីនរ៉ក់អន្តរជាតិយល់ព្រម ៖

- គោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ។
- ប្រើប្រាស់ពិធីសារអង្គការសហប្រជាជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងផ្តន្ទាទោស អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ, អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងបទឧក្រិដ្ឋឆ្លងដែន, អនុសញ្ញាស្តីពីសិទ្ធិស៊ីវិល និងនយោបាយ, អនុសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពក្នុងការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW), អនុសញ្ញាស្តីពីសិទ្ធិកុមារ, ច្បាប់ស្តីពីការប្រឆាំងអំពើជួញដូររបស់រាជរដ្ឋាភិបាលកម្ពុជា និងរាល់ក្របខ័ណ្ឌការងារ និងផែនការទាំងអស់របស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុម័តពាក់ព័ន្ធទៅនឹងការលើកកម្ពស់គោលបំណងនៃកម្មវិធីប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២ ។
- បំពេញតួនាទីរបស់ខ្លួនក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ភ នៅគ្រប់ទិដ្ឋភាពទាំងអស់ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការសម្រេចឲ្យបាននូវកម្មវិធី ប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២ ដែលបានឯកភាពគ្នា ។
- លើកកម្ពស់បទដ្ឋានក្រមសីលធម៌ និងគណនេយ្យភាពឱ្យមានកម្រិតខ្ពស់បំផុត ក្នុងការអនុវត្តន៍កម្មវិធីប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២ ក្រោមភាពជាដៃគូជិតស្និទ្ធជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ. រ.ព.ភ ។
- ផ្តល់ការគាំទ្រជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដល់គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ ដែលអនុម័តដោយ USAID ជារៀងរាល់ឆ្នាំ ។

សូមភ្ជាប់មកជាមួយនូវ ផែនការសកម្មភាពប្រចាំឆ្នាំ ដែលអនុម័តដោយ USAID ។

## ៤. ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ គឺជាជនបង្គោលដែលទទួលការប្រគល់សិទ្ធិពីគណៈកម្មាធិការជាតិ និងនាយកគំរោងកម្មវិធី អង្គការវីនរ៉ក់អន្តរជាតិប្រចាំនៅកម្ពុជា ជាជន

បង្គោលសម្រាប់ការអនុវត្តអនុស្សរណៈនេះ និងដើម្បីរក្សាការឃ្លាំមើលទូទៅតាមរយៈការប្រាស្រ័យទាក់ទងជាប្រចាំរវាងជនបង្គោលទាំងនេះ ។ ជនបង្គោល ត្រូវមានភារកិច្ចដូចខាងក្រោម ៖

- បង្កើតក្របខ័ណ្ឌការងារមួយ សម្រាប់ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហានានាដែលកើតឡើងក្នុងអំឡុងពេលអនុវត្ត ដោយតម្រូវឱ្យមានការចូលរួមពីអង្គការ USAID ទៅតាមភាពចាំបាច់។
- ជូនដំណឹងដល់អ្នកពាក់ព័ន្ធនានា រាប់បញ្ចូលទាំងអង្គការ USAID អំពីសកម្មភាពដែលកំពុងអនុវត្តក្រោមកម្មវិធីនេះ ទៅតាមភាពចាំបាច់ ។
- បង្កលក្ខណៈងាយស្រួលដល់ការផ្សព្វផ្សាយអំពីលទ្ធផលការងារនៃគម្រោងកម្មវិធី ដោយមានការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់រួមមាន៖ សមាជិកលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ក្រសួងពាក់ព័ន្ធ អង្គការវីនរ៉ក់ និង USAID និងចែករំលែកព័ត៌មានស្ដីពីសកម្មភាព ព្រឹត្តិការណ៍ និងកម្មវិធី ដែលពាក់ព័ន្ធទៅនឹងលទ្ធផលដែលសម្រេចបាន ។

## ៥. ការប្រាស្រ័យទាក់ទង និងភាសា

រាល់ការជូនដំណឹង សំណើរ ឯកសារ ឬការប្រាស្រ័យទាក់ទងដទៃទៀត ដែលផ្ដល់ជូនដោយភាគីណាមួយទៅកាន់ភាគីដទៃទៀត ក្រោមអនុស្សរណៈនៃការយោគយល់គ្នានេះ អាចធ្វើឡើងជាភាសាអង់គ្លេស ឬភាសាខ្មែរ ហើយនឹងត្រូវបានចាត់ទុកថាបានប្រគល់ ឬបញ្ជូនសមស្រប នៅពេលដែលត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរយៈជនបង្គោលទំនាក់ទំនង ដែលតែងតាំងដោយគណៈកម្មាធិការជាតិ និងអង្គការវីនរ៉ក់ ។

## ៦. លក្ខខ័ណ្ឌ

អនុស្សរណៈនៃការយោគយល់នេះ គឺជាផ្នែកមួយនៃក្របខ័ណ្ឌសម្របសម្រួលរវាងអង្គការវីនរ៉ក់ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំ សម្រាប់កម្មវិធីប្រឆាំងការជួញដូរមនុស្ស ។ កាលបរិច្ឆេទបញ្ចប់កម្មវិធីនេះ គឺថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ ។ អនុស្សរណៈនៃការយោគយល់នេះ អាចត្រូវបានបន្ត ឬធ្វើវិសោធនកម្ម ជាលាយលក្ខណ៍អក្សរ ដោយមានការយល់ព្រមទៅវិញទៅមកពីភាគីចូលរួម ។

## ៧. ការកែសម្រួល និងការបញ្ចប់កិច្ចព្រមព្រៀង

អនុស្សរណៈនៃការយោគយល់គ្នានេះអាចត្រូវបានកែសម្រួលដោយមានការយល់ព្រមលាយលក្ខណ៍អក្សរទៅវិញទៅមកពីភាគីអ្នកចូលរួម ។ ភាគីអ្នកចូលរួមណាមួយអាចបញ្ចប់កិច្ចព្រមព្រៀងនេះ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីអ្នកចូលរួមដទៃទៀត ។

## ៨. បទប្បញ្ញត្តិបន្ថែម

៨.១ អនុស្សរណៈនៃការយោគយល់គ្នានេះ ធ្វើឡើងជាពីរច្បាប់ ជាភាសាខ្មែរមួយច្បាប់ និងភាសាអង់គ្លេសមួយច្បាប់ ។ អត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់ ។

SAC

៨.២ អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមាន និងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដោយភាគីអ្នកចូលរួមទាំងពីរ ។

៨.៣ អនុស្សរណៈនៃការយោគយល់គ្នានេះ មិនមែនជា ឧបករណ៍ច្បាប់ ឬកាតព្វកិច្ចដោយភាគីអ្នកចូលរួមណាមួយឡើយ ហើយក៏មិនផ្តល់សិទ្ធិឲ្យភាគីទីបីដែរ ។

៨.៤ អនុស្សរណៈនៃការយោគយល់គ្នានេះមិនត្រូវជំនួស ឬជ្រៀតជ្រែកដោយកិច្ចព្រមព្រៀងណាមួយឡើយ ។ ភាគីអ្នកចូលរួម ដែលបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់នេះ និងមិនត្រូវអនុវត្តក្រៅពីអនុស្សរណៈ នៃការយោគយល់នេះឡើយ ។

ដើម្បីជាសាក្សីនៃអនុស្សរណៈនៃការយោគយល់គ្នានេះ លោក FLYNN FULLER ប្រធានបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ប្រចាំប្រទេសកម្ពុជា ចូលរួមជាសាក្សីទៅលើបទប្បញ្ញត្តិ ដែលបានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់នេះ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១២

**លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាប្រធានលេខាធិការដ្ឋាន**
**នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត**

**លោកស្រី សារ៉ា ភីហ្សាណូ**
**នាយកគំរោងកម្មវិធី**
**អង្គការវីនរ៉ក់អន្តរជាតិ**

**សាក្សី**

**លោក** FLYNN FULLER
**ប្រធានបេសកកម្ម**
**ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ** (USAID)